# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

១. ថ្ងៃ ខែ ឆ្នាំ ៖ ថ្ងៃអង្គារ ៨រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃអង្គារ ទី៧ ខែកក្កដា ឆ្នាំ២០២៦

២. ទីកន្លែង ៖ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធនិម្មិត(Zoom)។

៣. ប្រធាន និងសមាសភាពចូលរួម ៖

៣-១- ប្រធានអង្គប្រជុំ ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣-២- សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដែលមានសមាជិកចូលរួមនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចំនួន៣៥រូប និងតាមប្រព័ន្ធនិម្មិត(Zoom) ចំនួន៣៨គណនី។

៤. របៀបវារៈ៖

៤.១ មតិស្វាគមន៍ និងគោលបំណងរបស់ ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២ បទបង្ហាញស្តីពី ការកំណត់សកម្មភាពគន្លឹះដើម្បីអនុវត្តលើសេចក្តីសម្រេចចិត្ត កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៦។

៤.៣ ទិសដៅអនុវត្តក្នុងឆ្នាំ២០២៦។

៤.៤ មតិបូកសរុប និងបិទកម្មវិធីដោយ ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៥. សកម្មភាព និងលទ្ធផល ៖

**ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានថ្លែងនូវមតិស្វាគមន៍ដល់ក្រុមការងារ និងអង្គប្រជុំ ដោយបានថ្លែងនូវការកោតសរសើរក្រុមការងារ ក៏

ដូចជាក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលបានប្រឹងប្រែងចូលរួមក្នុងការអនុវត្តការឆ្លើយតបនឹងមេរោគអេដស៍រហូតទទួលបានជោគជ័យ៩៥-៩៥-៩៥ លើការឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍នៅតំបន់អាស៊ីប៉ាស៊ីហ្វិក នាពេលកន្លងមកថ្មីៗនេះ។ ការសម្រេចបាននូវលទ្ធផលល្អប្រសើរទាំងនេះ ក៏ដោយសារមានការយកចិត្តទុកដាក់គិតគូប្រកបដោយគតិបណ្ឌិតរបស់**សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** នៃ ព្រះរាជាណាចក្រកម្ពុជា ដោយមានចូលរួមអនុវត្តពីគ្រប់ភាគីពាក់ព័ន្ធទាំងថ្នាក់ជាតិ អន្តរជាតិ និងសង្គមស៊ីវិល ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃរបស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការឈានទៅសម្រេចបានគោលនយោបាយជាតិទាំងបី៖ ១-កាត់បន្ថយការចម្លងថ្មីតិចជាង ១នាក់ ឬប្រមាណជា ២០០នាក់ក្នុងមួយឆ្នាំ ២-កាត់បន្ថយការស្លាប់ដោយសារមេរោគអេដស៍ឱ្យនៅក្រោម ២០០នាក់ក្នុងមួយឆ្នាំ ៣- លុបបំបាត់ការមាក់ងាយ និងរើសអើង។

**ឯកឧត្តមបណ្ឌិត**ក៏បានបន្តថា សម្រាប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ស្របតាមការកិច្ចដូចមានចែងក្នុងឧបសម្ព័ន្ធទី១នៃគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨បង្កើនការយល់ដឹង ដើម្បីជំរុញការអនុវត្តឱ្យបានទូលំទូលាយទូទាំងប្រទេស និងពង្រឹងភាពជាម្ចាស់ក្នុងការពង្រឹងប្រព័ន្ធជាតិឆ្លើយតបជាពហុវិស័យចំពោះមេរោគអេដស៍ និងជំងឺអេដស៍ ព្រមទាំងលើកកម្ពស់ការយល់ដឹង និងប្រើប្រាស់មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ក្នុងការងារឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍ ឱ្យកាន់តែប្រសើរឡើងនូវយន្តការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ រវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ឯកឧត្តមបណ្ឌិត** បានអនុញ្ញាតលោកវេជ្ជ. ទេព ណាវុធ ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យវាយតម្លៃ និងស្រាវជ្រាវ បង្ហាញជូនការកំណត់សកម្មភាពគន្លឹះដើម្បីអនុវត្តលើសេចក្តីសម្រេចចិត្ត កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៦។ លោកក៏បានជម្រាបអង្គប្រជុំពី

- ការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។
- ស្ថានភាពអេពីដេមីសាស្ត្រ មេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជា។
- បច្ចុប្បន្នភាពមេរោអេដស៍ និងជំងឺអេដស៍ នៅកម្ពុជា។
- សេចក្តីសម្រេចកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៦។
- ផែនការយុទ្ធសាស្ត្រជាតិ ទូលំទូលាយនិងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៦ ឆ្នាំ២០២៤-២០២៨
- ច្បាប់ លិខិតបទដ្ឋានគតិយុត្តិ និងឯកសារពាក់ព័ន្ធសំខាន់ៗទាក់ទងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជា។

ជូនភ្ជាប់ជាមួយនូវឯកសារ។

ទន្ទឹមនឹងនោះ **ឯកឧត្តមបណ្ឌិត** បានរំលឹកឡើងវិញនូវជោគជ័យ ៩៥-៩៥-៩៥ ដែលទទួលបានលើការឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍នៅតំបន់អាស៊ីប៉ាស៊ីហ្វិក។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ មេរោគអេដស៍នៅតែបន្តមានជានិច្ច ប្រសិនបើយើងទាំងអស់គ្នាធ្វេសប្រហែសវានឹងផ្ទុះឡើងវិញ។ ហេតុដូចនេះ គ្រប់ក្រសួងស្ថាប័ន រាជធានី ខេត្ត អាជ្ញាធរមូលដ្ឋាន និងអង្គការសង្គមស៊ីវិល ដែលពាក់ព័ន្ធត្រូវតែបន្តអនុវត្តសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ ជំងឺអេដស៍ ដើម្បីកំណត់សកម្មភាពគន្លឹះសម្រាប់អនុវត្តឆមាសទី២ ឆ្នាំ២០២៦។

កិច្ចប្រជុំបានដំណើរការទៅតាមរបៀបវារៈដែលបានគ្រោងទុក និងបញ្ចប់នៅវេលាម៉ោង ១១:៣០នាទី ថ្ងៃខែឆ្នាំដដែល ប្រកបដោយលទ្ធផលផ្លែផ្កា។ ជាទីបញ្ចប់នៃកិច្ចប្រជុំ ឯកឧត្តមបណ្ឌិត បានជូនពរដល់សមាជិកអង្គប្រជុំ ឱ្យជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃអង្គារ ៩កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៦

បានឃើញ និងឯកភាព
ប្រធានអង្គប្រជុំ

បណ្ឌិត ឈឹម ឃិនដារ៉េត

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រកពជនជាន

វេជ្ជ. ហួត សេរីវឌ្ឍ

អ្នកធ្វើរបាយការណ៍

ស៊ុំ ផល្លា